# ការអនុវត្តន៍ល្អ

## ការប្រមូលសំរាម/កាកសំណល់



កន្លែងធ្វើការមួយដែលស្អាត អាចជួយសំរេចផលិតភាពកាន់តែប្រសើរជាងមុន ហើយការពារសុខភាព និងសុវត្ថិភាពដល់កម្មករ ។ រោងចក្រទាំងឡាយត្រូវបង្កើតប្រព័ន្ធដើម្បីធានាថា កាកសំណល់ត្រូវបានសំអាតជាប្រចាំ និងកន្លែងធ្វើការត្រូវបានថែរក្សាអោយមានសុវត្ថិភាព សុខភាព និងអនាម័យគ្រប់ពេលជានិច្ច ។

### *ការអនុវត្តន៍ល្អសំរាប់ការប្រមូលសំរាម*

កំទេចក្រណាត់ចេញពីម៉ាស៊ីនដេរ អាចធ្លាក់ចូលទៅក្នុងធុងសំរាមខាងក្រោមតុដេរដោយស្វ័យប្រវត្តិ ។ ត្រូវចោះប្រហោងក្នុងតុដេរ ហើយភ្ជាប់ប្រហោងនោះជាមួយនឹងធុងសំរាមតាមបំពង់បង្ហូរ ដែលអាចរអិលបានស្រួល (រូបភាពទី១) ។

ប្រើធុងសំរាម ដើម្បីប្រមូលកាកសំណល់នៅក្នុងរោងចក្រ (រូបភាពទី២) ។

លើកទឹកចិត្តកម្មករ អោយរក្សាកន្លែងធ្វើការអោយបានស្អាតជាប្រចាំ ។

ម៉ាស៊ីនដេរនីមួយៗគួរមានធុងសំរាមមួយ (រូបភាពទី៣) ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្កើនផលិតភាព
- ✓ លើកកំពស់សុខភាពល្អ និងមានសុវត្ថិភាពដល់កម្មករគ្រប់រូប
- ✓ បង្កើតទំលាប់គេហកិច្ចល្អ
- ✓ ជួយបង្កើតវប្បធម៌សុខភាពល្អប្រសើរនៅកន្លែងធ្វើការ នៅក្នុងរោងចក្រ

### តាមរបៀបណា:

- ✓ ប្រើប្រាស់កន្ត្រក/ធុង តាមកន្លែងត្រឹមត្រូវ នៅគ្រប់កន្លែងធ្វើការទាំងអស់
- ✓ លើកទឹកចិត្តកម្មករអោយបង្កើតទំលាប់ល្អ ទោះបីជាក្នុងពេលដែលរវល់ក៏ដោយ

### តំលៃ:

**$**

- **$** តំលៃទាប
- **$$** តំលៃមធ្យម
- **$$$** តំលៃខ្ពស់